## ២.៩ ការពង្រីកការអប់រំក្រៅប្រព័ន្ធ

### វត្ថុបំណង និង យុត្តិកម្ម

កម្មវិធីអប់រំក្រៅប្រព័ន្ធនឹងជួយធានាថា កុមារ និងជនពេញវ័យទាំងអស់ បានយល់ដឹងពីសិទ្ធិរបស់ពួកគេក្នុងការទទួលការអប់រំកំរិតមូលដ្ឋាន ។ កម្មវិធីអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្តល់ជូនដល់ជនក្រីក្រដែលមិនបានចូលរៀននៅកំរិតមូលដ្ឋាន នៃប្រព័ន្ធអប់រំចំណេះទូទៅ ។

ផលសម្រេចជាចម្បងនៃកម្មវិធីនេះគឺ ផ្តល់ការចូលរៀនឡើងវិញ និងការចូលរៀនបំពេញវិជ្ជាប្រកបដោយចំណាយមានប្រសិទ្ធភាព និងគុណភាពខ្ពស់ និងកម្មវិធីវាយតម្លៃជំនាញ ដែលបានជ្រើសរើសមួយចំនួននៅក្នុងសហគមន៍ តាមរយៈការអប់រំក្រៅប្រព័ន្ធ ។

ជួយសម្រួលដល់ការចូលរៀនឡើងវិញនៅក្នុងប្រព័ន្ធចំណេះទូទៅ ទន្ទឹមនឹងការផ្តល់កម្មវិធីបំពេញវិជ្ជា នឹងធ្វើឱ្យប្រជាជនកម្ពុជាចូលរួមបានកាន់តែល្អប្រសើរនៅក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ ដែលជាមធ្យោបាយសំខាន់មួយដើម្បីកាត់បន្ថយភាពក្រីក្រ ។

### អាំងឌីកាទ័រ និង ចំណុចដៅចម្បងៗ

- ពង្រីកកាលានុវត្តភាពចូលរៀនឡើងវិញសម្រាប់យុវជននៅក្រៅសាលារៀន ពី ១៩,៤៧៦ នាក់ (ស្រី ៤៥%) (អត្រាជោគជ័យប្រហែល ៧៥%[១]) នៅឆ្នាំសិក្សា ២០០៤-២០០៥ ដល់ ២៥,០០០ នាក់រៀងរាល់ឆ្នាំ (ចំណុចដៅ ស្រី ៦០%) នៅថ្នាក់ទី ៣-៦ ចាប់ពីឆ្នាំ ២០០៦ ទៅ ។ សិស្សចំនួន ៥,០០០ នាក់នៅថ្នាក់ទី ៧-៩ រៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០០៨ តទៅ ។
- សហការជាមួយអ្នកផ្តល់សេវារបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីពង្រីកកម្មវិធីសមមូលសម្រាប់សិស្សប្រហែល ៥,០០០ នាក់នៅឆ្នាំសិក្សា ២០០៤-២០០៥ ដល់ ៣,០០០ នាក់ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០០៦ ទៅ (ថ្នាក់ទី ៣-៦ ១៥,០០០ នាក់ ថ្នាក់ទី ៧-៩ ១០,០០០ នាក់ ថ្នាក់ទី ១០-១២ ៥,០០០ នាក់) ។ ចំណុចដៅនេះមានស្រី ៦០% ។
- ពង្រីកការចូលរៀនតាមកម្មវិធីអក្ខរកម្ម បំណិនជីវិត កម្មវិធីរកប្រាក់ចំណូលបន្ថែមសម្រាប់យុវជន និងមនុស្សពេញវ័យទីទ័លក្រ ចំនួន ១១២,៥៩៧ នាក់ (ស្រី ៦៣%) នៅឆ្នាំសិក្សា ២០០៤-២០០៥ ទៅ ១២០,០០០ នាក់រៀងរាល់ឆ្នាំ ។ យ៉ាងហោចណាស់ស្រី ៦០% ។

### យុទ្ធសាស្ត្រ និង វិសាលភាព

---

[១] ផ្អែកលើអត្រាជោគជ័យ នៃកម្មវិធីចូលរៀនឡើងវិញ នៅឆ្នាំសិក្សា ២០០៣-០៤ ។

ក្រុមជនមុខសញ្ញាជាសំខាន់នោះគឺ សិស្សបោះបង់ការសិក្សាតិចជាង ៣ ឆ្នាំ ព្រមទាំងក្រុមជនងាយរងគ្រោះនៅតាមតំបន់ដាច់ស្រយាល ក្រុមជនជាតិភាគតិច និងក្រុមជនរស់នៅតាមតំបន់ជាប់ព្រំដែន ។ អាទិភាពចម្បងរបស់កម្មវិធីនេះគឺ ផ្តោតការយកចិត្តទុកដាក់ទៅលើកម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីសមមូលសម្រាប់យុវជននៅក្រៅសាលារៀន ។ វត្ថុបំណងសំខាន់មួយទៀតគឺ ពង្រីកកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេសផ្សេងៗទៀត ព្រមទាំងទីភ្នាក់ងារក្រៅរដ្ឋាភិបាល រួមមានអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ជាពិសេសនៅថ្នាក់សហគមន៍ ។

ដោយសារតែធនធានមានកំរិត ក្រសួងអប់រំ យុវជន និង កីឡា នឹងពិនិត្យឡើងវិញលើវិសាលភាព និងលទ្ធភាពអាចធ្វើបាន នៅក្នុងការផ្តួចផ្តើមកម្មវិធីអក្ខរកម្ម និង បំណិនជីវិតសម្រាប់ក្រុមយុវជន និង ជនពេញវ័យដែលជួបការលំបាក ដែលនេះជាមធ្យោបាយមួយ ដើម្បីពង្រឹងសមត្ថភាពមូលដ្ឋានក្នុងការរកចំណូល បច្ចេកទេសថ្មីៗក្នុងរបរកសិកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ព្រមទាំងផ្តោតការយកចិត្តទុកដាក់លើបំណិនជីវិតសម្រាប់បង្ការទប់ស្កាត់មេរោគហ៊ីវ/ជំងឺអេដស៍ និងបញ្ហាសុខភាពផ្សេងៗ ។ កម្មវិធីទាំងនេះនឹងត្រូវបង្កើនធនធានតាមរយៈភាពជាដៃគូរវាងផ្នែកសាធារណៈ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ ហើយចាំបាច់ត្រូវប្រើប្រាស់យុទ្ធសាស្ត្រដែលមានភាពទន់ភ្លន់ សម្រាប់គាំទ្រដល់ការបង្រៀន និងសម្ភារបរិក្ខារ ។

**កម្មវិធី និង សកម្មភាពចម្បងៗ**

១. ពង្រីកកម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីសមមូល ៖ សកម្មភាពនានារួមមាន ក) គាំទ្រថវិកាសម្រាប់ដំណើរការកម្មវិធី ដើម្បីពង្រីកកម្មវិធីចូលរៀនឡើងវិញ ចំពោះសិស្សបោះបង់ការសិក្សា ខ) អភិវឌ្ឍកម្មវិធីសមមូល និងកម្មវិធីចូលរៀនឡើងវិញ និងការធ្វើតែស្តផ្អែកលើស្តង់ដាអប្បបរមា និង គ) ធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា និងសម្ភារៈសិក្សា ។

២. ពង្រីកកម្មវិធីអក្ខរកម្ម/បំណិនជីវិត ៖ សកម្មភាពនឹងផ្តោតទៅលើការពិនិត្យឡើងវិញនូវជំរើសសម្រាប់ធ្វើឱ្យមាននិរន្តរភាពនៃការផ្តល់យុទ្ធសាស្ត្រអក្ខរកម្មវិជ្ជាជីវៈ និងបំណិនជីវិត ដោយគិតទាំងការផ្សារភ្ជាប់ទៅនឹងការបណ្តុះបណ្តាលបំណិនក្រៅប្រព័ន្ធ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងជួយសម្រួលភាពជាដៃគូរវាងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល សហគមន៍ និងកម្មវិធីបង្រៀនពីរភាសា សម្រាប់ជនជាតិភាគតិច ។

៣. ពង្រឹង និងពង្រីកមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមជ្ឈមណ្ឌលសម្រាប់អាន ដើម្បីលើកកំពស់ចំណេះដឹង និងផ្តល់ការគាំទ្រដល់អក្ខរជនថ្មី ។

៤. លើកកំពស់សមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ ៖ សកម្មភាពនានារួមមាន ក) ពង្រឹងសមត្ថភាពមន្ត្រីនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងសហគមន សម្រាប់កំណត់ចំណុចដៅ ការកសាងផែនការ និងការ គ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ ខ) ពង្រឹងប្រព័ន្ធព័ត៌មានអប់រំក្រៅប្រព័ន្ធដែលជាមូលដ្ឋាន

មួយសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការវិភាគតម្រូវការសិក្សា ការកំណត់ភាពក្រីក្រ ការវាយតម្លៃប្រសិទ្ធិភាពចំណាយ ការពិនិត្យតាមដានកម្មវិធី និងកែលំអការសម្របសម្រួលដល់គំនិតផ្តួចផ្តើមរបស់ភ្នាក់ងារក្រៅរដ្ឋាភិបាល ។

៥. ពង្រឹងរចនាសម្ព័ន្ធការងារអប់រំក្រៅប្រព័ន្ធ ពីថ្នាក់កណ្តាលដល់សហគមន៍ ។

៦. សម្របសម្រួលការពិនិត្យតាមដានកម្មវិធី សម្រាប់គាំទ្រដំណើរការកិច្ចប្រតិបត្តិការរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ចំពោះការកសាងផែនការ រួមទាំងការរៀបចំរបាយការណ៍ស្តីពីផលប៉ះពាល់នានា ។

៧. ផ្តល់បំណិនជីវិតមិត្តអប់រំមិត្តដល់យុវជនក្រៅសាលា ស្ថិតក្រោមកម្មវិធីមេរោគហ៊ីវ/ជម្ងឺអេដស៍ ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន[២] ។

### ការគ្រប់គ្រង និង ការពិនិត្យតាមដានកម្មវិធី

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ទទួលខុសត្រូវលើការគ្រប់គ្រងកម្មវិធីរួម ដែលរួមមានរៀបចំគំរោងធ្វើអន្តរាគមន៍ ការកំណត់ចំណុចដៅ ការកសាងផែនការ ការធានាគុណភាព និងការពិនិត្យតាមដាន ជាមួយគ្នានឹងការផ្តោតទៅលើកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានផ្សេងៗទៀត ថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ក្រសួងផ្សេងៗទៀត សហគមន៍ និង អង្គការក្រៅរដ្ឋាភិបាល ។ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ផ្តល់នាទីនេះដល់អង្គភាពគ្រប់គ្រងថវិកាសម្រាប់ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ។ អង្គភាពនេះផ្តល់កញ្ចប់ថវិកាប្រចាំឆ្នាំដល់ខេត្ត-ក្រុង និងជួយជ្រោមជ្រែងសម្រាប់ការកសាងផែនការកម្មវិធី ។ នាយកដ្ឋាននឹងរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការរីកចម្រើន និងផលប៉ះពាល់របស់កម្មវិធីនេះ ដោយផ្អែកលើទិន្នន័យដែលទទួលបានពីខេត្ត-ក្រុង ។

ត្រូវពិនិត្យឡើងវិញការរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុ ។ ជម្រើសនានារួមមាន ការផ្តល់មូលនិធិអប់រំក្រៅប្រព័ន្ធផ្អែកលើតម្រូវការ ឬការប្រើប្រាស់អង្គភាពគ្រប់គ្រងថវិកាថ្នាក់ខេត្ត-ក្រុង និង ស្រុក-ខ័ណ្ឌ ។ គោលការណ៍ណែនាំត្រូវមានភាពទន់ភ្លន់ និងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព និង ការផ្តល់កម្មវិធីសំបូរបែបដល់ក្រុមសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល ។

## ផែនការហិរញ្ញវត្ថុ

ផែនការហិរញ្ញវត្ថុ ឆ្លុះបញ្ចាំងពីការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើកម្មវិធីចូលរៀនឡើងវិញ ដើម្បីដោះស្រាយបញ្ហាសិស្សបោះបង់ការសិក្សា ។ ការកៀរគរការចូលរួមពីភ្នាក់ងារក្រៅរដ្ឋាភិបាល រួមទាំងភាពជាដៃគូពីសហគមន៍ ផ្នែកឯកជន និងការបំពេញបន្ថែមពីសំណាក់អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល ពិតជាមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់គំនិតផ្តួចផ្តើមកម្មវិធីអក្ខរកម្ម/បំណិនជីវិត ។

---

[២] *មានការគាំទ្រ តាមរយៈគណៈកម្មការអន្តរនាយកដ្ឋានស្តីពីមេរោគហ៊ីវ/ជម្ងឺអេដស៍ (ICHA) ។*

*តារាងទី ៩ : ផែនការហិរញ្ញវត្ថុសម្រាប់ការពង្រីកការអប់រំក្រៅប្រព័ន្ធ*

| សកម្មភាព | ចំណាយគិតជាលានរៀល | | | | |
|---|---|---|---|---|---|
| | **2006** | **2007** | **2008** | **2009** | **2010** |
| ១. ការពង្រីកកម្មវិធីចូលរៀនឡើងវិញ/សមមូល | 5,000 | 4,600 | 5,800 | 6,000 | 6,200 |
| ២. ការពង្រីកកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ/បំណិនជីវិត | 1,000 | 1,000 | 1,000 | 1,500 | 1,500 |
| ៣. ការលើកកំពស់សមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ | 200 | 200 | 200 | 250 | 300 |
| ៤. ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី | 500 | 500 | 500 | 600 | 600 |
| **ថវិកាសរុប** | **6,700** | **6,300** | **7,500** | **8,350** | **8,400** |

## តម្រូវការកសាងសមត្ថភាព

- ពង្រឹងសមត្ថភាពនៅថ្នាក់កណ្តាល ខេត្ត-ក្រុង និងសហគមន៍ សម្រាប់ការកំណត់ចំណុចដៅ ការកសាងផែនការ និងការគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ ។
- ពង្រឹងប្រព័ន្ធព័ត៌មានអប់រំក្រៅប្រព័ន្ធ ដែលជាមូលដ្ឋានសម្រាប់ការវិភាគតំរូវការសិក្សា ការកំណត់ភាពក្រីក្រ ការវាយតម្លៃអំពីចំណាយមានប្រសិទ្ធភាព ការពិនិត្យតាមដានកម្មវិធី និង កែលំអការសម្របសម្រួលជាមួយគំនិតផ្តួចផ្តើមរបស់អង្គការក្រៅរដ្ឋាភិបាល ។
- គាំទ្រដល់ការរៀបចំយុទ្ធសាស្ត្រស្ថាប័ន និងការគ្រប់គ្រង ដើម្បីពង្រឹងរចនាសម្ព័ន្ធអប់រំក្រៅប្រព័ន្ធពីថ្នាក់កណ្តាល ដល់សហគមន៍ ។